# គណៈកម្មការទ្រទ្រង់សាលារៀនធ្វើជាស្ពានរវាងសាលារៀន និងសហគមន៍

ដោយសារចំណេះដឹង និងសកម្មភាពខ្លួនកើនឡើង គណៈកម្មការទ្រទ្រង់សាលារៀន បានគាំទ្រសាលារៀន និងសហគមន៍របស់ខ្លួន ដើម្បីកែលម្អទំនាក់ទំនងរវាងអ្នកជាប់ពាក់ព័ន្ធគ្រប់រូប។

ទោះបីជាគាត់រស់នៅចម្ងាយ ១គីឡូម៉ែត្រពីសាលាបឋមសិក្សារបស់កូនស្រីគាត់ក៏ដោយ សែន ពេជ្រ ដែលជាកសិករមកពីភូមិពូហ្យាម ក្នុងខេត្តមណ្ឌលគិរី ជាធម្មតាមមាញឹកជាមួយការងារប្រចាំថ្ងៃរបស់គាត់ពេក គាត់មិនអាចទៅមើលសាលារៀនរបស់កូនគាត់បានទៀងទាត់នោះទេ។

ទោះបីជាពីមុនគាត់អាចមានបញ្ហាទាក់ទងនឹងការដែលគាត់មិនបានដឹងអំពីការអភិវឌ្ឍសាលារៀនក៏ដោយ ក៏ប៉ុន្តែចាប់តាំងពីគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ពូហ្យាម មានភាពសកម្មមកគាត់បានទទួលដំណឹងល្អប្រសើរច្រើនជាងមុន។

ស្ត្រីជនជាតិភាគតិចព្នងរូបនេះពន្យល់ថា ៖ "ខ្ញុំបានដឹងការប្រជុំជាមួយឪពុកម្តាយ[សិស្ស] នៅថ្ងៃនេះពីសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន"។

[គាត់បន្តថា] ៖ "ពេលខ្លះខ្ញុំរវល់ណាស់ ដូច្នេះខ្ញុំមិនអាចទៅសាលារៀនបានទេ តែឥឡូវរបៀបដែលសាលារៀនផ្សព្វផ្សាយសារអំពីការប្រជុំ គឺងាយស្រួលទទួលបានដំណឹង។ ប្រសិនបើមានព័ត៌មានថ្មីៗ សាលារៀនប្រាប់គណៈកម្មការ ហើយបន្ទាប់មកសមាជិកដែលជាជនបង្គោលក្នុងជួរគណៈកម្មការនៅក្នុងភូមិ ធ្វើការផ្សព្វផ្សាយដល់ឪពុកម្តាយ[សិស្ស]"។

អ៊ីវ សុខខឿន ជាសមាជិកគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ពូហ្យាម និងជាអនុប្រធានភូមិបញ្ជាក់ថា តាំងពីពេលសមាជិក[គណៈកម្មការ]បានចូលរួមក្នុងការបណ្តុះបណ្តាលមួយស្តីពីតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ដែលរៀបចំដោយអង្គការឃែរ ពួកគេបានចាប់ផ្តើមធ្វើជាស្ពានរវាងសាលារៀន និងសហគមន៍។

អ៊ីវ សុខខឿន ដែលចុះទៅជួបម្តាយឪពុក[សិស្ស]ដល់ផ្ទះជាទៀងទាត់នោះបញ្ជាក់ថា ៖ "ឥឡូវទំនាក់ទំនងរវាងឪពុកម្តាយ[សិស្ស]និងសាលារៀនបានល្អប្រសើរហើយ ដោយសារតែសកម្មភាពរបស់គណៈកម្មការ"។

យោងតាម ស៊ុន ម៉ៅ អាយុ៣៥ឆ្នាំ ជានាយកសាលាបឋមសិក្សាដាក់ដាំ បានឱ្យដឹងថា ស្ថានភាពស្រដៀងគ្នានេះក៏កំពុងកើតមានឡើងនៅក្នុងសាលាបឋមសិក្សាដាក់ដាំ ដែរ។

ស៊ុន ម៉ៅ ដែលពីមុនធ្វើគ្រូបង្រៀនហើយឥឡូវបានក្លាយជានាយកសាលានិយាយថា ៖ "ពីមុនគណៈកម្មការទ្រទ្រង់សាលារៀន មិនសូវជាធ្វើអ្វីទេ។ ពួកគេគ្រាន់តែដឹងថា ពួកគេជាសមាជិកគណៈកម្មការតែពួកគេមិនដឹងពីតួនាទីរបស់ពួកគេនោះទេ។ បន្ទាប់ពីការបណ្តុះបណ្តាលស្តីពីតួនាទីរបស់ពួកគេមកទើបពួកគេដឹងថា គេត្រូវធ្វើអ្វីខ្លះ"។

គាត់បន្តថា ៖ "ឥឡូវបើមានបញ្ហាអ្វីមួយ ខ្ញុំសុំឱ្យពួកគេជួយ។ ឧទាហរណ៍៖ ថ្ងៃនេះគណៈកម្មការត្រូវចូលរួមប្រជុំជាមួយអាជ្ញាធរសាលារៀន ដូច្នេះខ្ញុំក៏ទូរសព្ទទៅពួកគេដើម្បីឱ្យពួកគេផ្តល់ដំណឹងទៅអ្នកដទៃទៀតអំពីការប្រជុំនេះ"។

ព្យុយ ផាន្នី ភេទស្រី ជនដើមភាគតិចព្នង ជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនយល់ស្របជាមួយនាយកសាលា ម៉ៅ។ គាត់និយាយថា ដោយសារការប្រជុំប្រចាំខែជាមួយអ្នកពាក់ព័ន្ធ ធ្វើឱ្យទំនាក់ទំនងរវាងសហគមន៍ និងឪពុកម្តាយ[សិស្ស]មានការផ្លាស់ប្តូរយ៉ាងខ្លាំង។


© Nicolas Axelrod / Ruom / CARE

*"ពេលខ្លះខ្ញុំរវល់ណាស់ ដូច្នេះខ្ញុំមិនអាចទៅសាលារៀនបានទេ តែឥឡូវរបៀបដែលសាលារៀនផ្សព្វផ្សាយសារអំពីការប្រជុំ គឺងាយស្រួលទទួលបានដំណឹង។ ប្រសិនបើមានព័ត៌មានថ្មីៗ សាលារៀនប្រាប់គណៈកម្មការ ហើយបន្ទាប់មកសមាជិកដែលជាជនបង្គោលក្នុងជួរគណៈកម្មការនៅក្នុងភូមិ ធ្វើការផ្សព្វផ្សាយដល់ឪពុកម្តាយ[សិស្ស]"។*

[គាត់ពន្យល់ថា] ៖ "ទំនាក់ទំនងរវាងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន និងសហគមន៍បានផ្លាស់ប្តូរជាពិសេសឥឡូវមានការប្រជុំច្រើន។ ឥឡូវយើងចែករំលែកព័ត៌មានរវាងសាលារៀនគណៈកម្មការ និងសហគមន៍ ឧទាហរណ៍៖ បើមានសិស្សឈឺ យើងនឹងប្រាប់សាលារៀន ហើយដូចគ្នានេះដែរបើសិស្សមិនមករៀន យើងនឹងទៅទាក់ទងឪពុកម្តាយរបស់ពួកគេ" ។

ស្រដៀងគ្នានេះដែរ យោងតាមសហការីរបស់គាត់ឈ្មោះ ប្លង់ សេង ដែលជាមេភូមិ បានឱ្យដឹងថា សមាជិកសហគមន៍ទៅរកតំណាងសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីលើកឡើងពីការមិនសុខចិត្ត និងក្តីកង្វល់ទាក់ទងនឹងសាលារៀន និងការអប់រំ។

គាត់និយាយថា៖ "ប្រជាជនក្នុងសហគមន៍មករកខ្ញុំដើម្បីនិយាយអំពីបញ្ហាដែលពួកគេមានជាមួយសាលារៀន"។

ប្លង់ សេង ដែលបានកាន់មុខតំណែងជាមេភូមិអស់រយៈពេល ១៤ឆ្នាំមកហើយនេះកត់សម្គាល់ថា សំណាងដែរគណៈកម្មការមានសមាសភាពមកពីសមាជិកសហគមន៍ខុសៗគ្នា ដូច្នេះពួកគេអាចទាក់ទងជាមួយសហការីរបស់ពួកគេដោយងាយស្រួល។

គាត់ពន្យល់ថា៖ "កាលពីមុនសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនទាំងអស់ជាគ្រូបង្រៀន" និងបន្ថែមថា៖ "ដូច្នេះវាពិតជាល្អដែលថាឥឡូវនេះយើងមានសមាជិកសហគមន៍ធ្វើសមាជិកគណៈកម្មការ"។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

© CARE Cambodia, September 2016